**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ភ្នំពេញ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤

**ទីប្រឹក្សាជាតិស្តីពីការសិក្សាគំរូការចែករំលែកផលប្រយោជន៍រេដ+កម្ពុជា**
**សូមគោរពជូន**
**ឯកឧត្តមប្រធានក្រុមការងាររេដ+កម្ពុជា**

**កម្មវត្ថុ** ៖ របាយការណ៍កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិស្តីពីការសិក្សាគំរូការចែករំលែកផលប្រយោជន៍រេដ+កម្ពុជា នៅខេត្តកំពង់ធំ។

**យោង** ៖ កិច្ចព្រមព្រៀង ចុះថ្ងៃទី ខែ ឆ្នាំ២០១៤។

ន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមអនុញ្ញាតជម្រាបជូនឯកឧត្តមប្រធានក្រុមការងាររេដ+កម្ពុជាមេត្តាជ្រាបថា ក្រុមទីប្រឹក្សាជាតិបានសហការជាមួយក្រុមការងារបច្ចេកទេសចែករំលែកផលប្រយោជន៍រេដ+បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ស្តីពីការសិក្សាគំរូការចែករំលែកផលប្រយោជន៍រេដ+កម្ពុជា ដែលទទួលបានលទ្ធផលដូចខាងក្រោម ៖

**១ សេចក្តីផ្តើម**

ប្រទេសកម្ពុជាបាននិងកំពុងអនុវត្តផែនទីបង្ហាញផ្លូវស្តីពីរេដ+ដែលក្នុងនោះក្រុមការងាររេដ+កម្ពុជាបាននិងកំពុងរៀបចំនូវគោលនយោបាយនិងលិខិតបទដ្ឋាន ក្នុងគោលដៅធានាបាននូវការអនុវត្តកម្មវិធីរេដ+កម្ពុជាប្រកបដោយប្រសិទ្ធភាព និងរួមចំណែកដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការបាត់បង់និងរេចរឹលព្រៃឈើ ជាក់ស្តែងការរៀបចំឲ្យមានកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិស្តីពីការសិក្សាគំរូការចែករំលែកផលប្រយោជន៍រេដ+កម្ពុជាគឺជាផ្នែកមួយនៃដំណើរការរៀបចំគោលនយោបាយ និងយន្តការប្រកបដោយប្រសិទ្ធភាព។

ក្រុមការងារនឹងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិនេះចំនួន១០លើក នៅក្នុង១០ខេត្ត ទៅតាមផែនការដែលបានគ្រោងទុកដូចខាងក្រោម ៖

| ល.រ | ខេត្តគោលដៅ | ពេលវេលារៀបចំ | ផ្សេងៗ |
|---|---|---|---|
| ១ | កំពង់ធំ | ១១ មីនា ២០១៤ | |
| ២ | ព្រះវិហារ | ២៤ មីនា ២០១៤ | |
| ៣ | ឧត្តរមានជ័យ | ២៦ មីនា ២០១៤ | |
| ៤ | សៀមរាប | ៣១ មីនា ២០១៤ | |
| ៥ | បាត់ដំបង | ០៩ មេសា ២០១៤ | |
| ៦ | ពោធិ៍សាត់ | ១១ មេសា ២០១៤ | |
| ៧ | មណ្ឌលគិរី | ២៣ មេសា ២០១៤ | |
| ៨ | ក្រចេះ | ២៥ មេសា ២០១៤ | |
| ៩ | ស្ទឹងត្រែង | ២៨ មេសា ២០១៤ | |
| ១០ | រតនគិរី | ៣០ មេសា ២០១៤ | |

## ២ លទ្ធផល

- **នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៤ នៅសណ្ឋាគារពន្លឺថ្មី ខេត្តកំពង់ធំ** ក្រុមទីប្រឹក្សាជាតិសហការជាមួយក្រុមការងារបច្ចេកទេសចែករំលែកផលប្រយោជន៍រេដ+ បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិស្តីពីការសិក្សាគំរូការចែករំលែកផលប្រយោជន៍រេដ+កម្ពុជា និងមានការអញ្ជើញចូលរួមជាកិត្តិយសដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកកិច្ចប្រជុំដោយឯកឧត្តម **ហ៊ិន អៀង** នាយអធិការដ្ឋានរដ្ឋបាលព្រៃឈើខាងជើងបឹងទន្លេសាប នៃរដ្ឋបាលព្រៃឈើ។
- កិច្ចប្រជុំនេះមានការចូលរួមពី ក្រុមការងារបច្ចេកទេសចែករំលែកផលប្រយោជន៍រេដ+ មន្ទីរជុំវិញខេត្ត សាលាស្រុក ក្រុមប្រឹក្សាឃុំ សហគមន៍មូលដ្ឋាន (សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារ សហគមន៍ជលផល និងសហគមន៍ជនជាតិដើមភាគតិច) និងអង្គការដៃគូ សរុបចំនួន៥១នាក់។
- កិច្ចប្រជុំបានប្រព្រឹត្តទៅដោយមានការធ្វើបទបង្ហាញដើម្បីចែករំលែកនូវទស្សនទាន និងបទពិសោធន៍ពាក់ព័ន្ធនឹងរេដ+ និងការចែករំលែកផលប្រយោជន៍ក្នុងវិស័យព្រៃឈើ រួមមាន ៖
    - បទបង្ហាញស្តីពីទស្សនទានរេដ+
    - បទបង្ហាញស្តីពីទស្សនទាននៃផលប្រយោជន៍
    - បទបង្ហាញស្តីពីទស្សនទាននៃ៣E
    - បទបង្ហាញស្តីពីការចែករំលែកផលប្រយោជន៍នៅសហគមន៍ព្រៃឈើឫស្សីជ្រុំ
- ក្នុងកិច្ចប្រជុំនេះដែរ ក៏មានការបែងចែកជាក្រុមពិភាក្សាចំនួន០៤ ៖
    1. ក្រុមមន្ទីរជុំវិញខេត្ត
    2. ក្រុមអាជ្ញាធរស្រុក និងឃុំ
    3. ក្រុមសហគមន៍មូលដ្ឋាន
    4. ក្រុមអង្គការក្រៅរដ្ឋាភិបាលក្នុងខេត្ត
- ក្រុមនិមួយៗបានធ្វើការពិភាក្សាលើសំនួរចំនួន០៤ គឺ ៖
    1. តើអង្គភាពរបស់អ្នកមានសកម្មភាពអ្វីខ្លះពាក់ព័ន្ធនឹងវិស័យព្រៃឈើ?
    2. តើអង្គភាពរបស់អ្នកបានទទួលផលប្រយោជន៍អ្វីខ្លះពីសកម្មភាពទាំងនេះ?
    3. តើអង្គភាពរបស់អ្នកមានយន្តការចែករំលែកផលប្រយោជន៍ដូចម្តេច?
    4. តើអង្គភាពរបស់អ្នកមានមានយន្តការលំហូរថវិការបបៀបណាខ្លះ?

## ៣ ភាពប្រឈម

តាមរយៈការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ស្តីពីការសិក្សាគំរូការចែករំលែកផលប្រយោជន៍រេដ+កម្ពុជា ក្រុមការងារជួបប្រទះនូវភាពប្រឈមមួយចំនួនដូចខាងក្រោម ៖

- អ្នកចូលរួមមួយចំនួនធំពុំទាន់យល់ពីទស្សនទានរេដ+ ដែលធ្វើឲ្យក្រុមការងារចំណាយពេលវេលាច្រើនក្នុងការពន្យល់

## ៤ សំណូមពរ

តាមផែនការដែលបានគ្រោងទុក ក្រុមការងារនឹងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិនេះបន្តជាប់គ្នាពីខេត្តមួយទៅខេត្តមួយ។ ដូចនេះដើម្បីអាចដំណើរកិច្ចប្រជុំនេះបានទាន់ពេលវេលា ខ្ញុំសូមសំណូមពរដល់លេខាធិការដ្ឋានរេដ+កម្ពុជាមេត្តាជួយសម្រួលផ្តល់បុរេប្រទានថវិកាឲ្យបានទាន់ពេលវេលា។

## ៤. សន្និដ្ឋាន

កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ស្តីពីការសិក្សាគំរូការចែករំលែកផលប្រយោជន៍រេដ+កម្ពុជា មានការចាប់អារម្មណ៍ និងចូលរួមយ៉ាងសកម្មពីភាគីអ្នកពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ។ កិច្ចប្រជុំនេះពិតជាមានសារសំខាន់ក្នុងការប្រមូលនូវព័ត៌មាន និងបទពិសោធន៍ដើម្បីយកមករៀបចំនូវគោលនយោបាយ និងយន្តការនៃការបែងចែកផលប្រយោជន៍រេដ+ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងសមធម៌។

កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ក្រោមជាតិដែលធ្វើឡើងនេះក៏ជាការរួមចំណែកដល់ការបង្កើនចំណេះដឹង និងសមត្ថភាពពីទស្សទានរេដ+ដល់ភាគីពាក់ព័ន្ធ ជាពិសេសបានរួមចំណែកដល់ការចូលរួមគ្រប់គ្រងធនធានព្រៃឈើប្រកបដោយនិរន្តភាព ជួយកាត់បន្ថយភាពក្រីក្រជនបទ និងរួមចំណែកដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការបាត់បង់ និងរេចរឹលព្រៃឈើ។

**<u>សូមជូនភ្ជាប់មកជាមួយនូវ</u>** ៖

- របាយការណ៍បច្ចេកទេសនៃកិច្ចប្រជុំ ចំនួន០១ច្បាប់។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រធានមេត្តាជ្រាបជាសេចក្តីរាយការណ៍ដោយក្តីអនុគ្រោះតាមការគួរ។